ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
# កោះឈើទាលតូច
## រយៈពេល ៣ ឆ្នាំ (២០២០ - ២០២២)

ឈ្មោះសហគមន៍នេសាទ ៖ កោះឈោះទាលតូច
ភូមិ ៖ កោះឈោះទាលតូច
ឃុំ ៖ ព្រះរំកិល
ស្រុក ៖ បុរីអូរស្វាយសែនជ័យ
ខេត្ត ៖ ស្ទឹងត្រែង

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
# កោះឈើទាលតូច
# រយៈពេល ៣ ឆ្នាំ (២០២០- ២០២២)

| | |
|---|---|
| សហគមន៍នេសាទ | ៖ កោះឈើទាលតូច |
| ភូមិ | ៖ កោះឈើទាលតូច |
| ឃុំ | ៖ ព្រះរំកិល |
| ស្រុក | ៖ បុរីអូរស្វាយសែនជ័យ |
| ខេត្ត | ៖ ស្ទឹងត្រែង |

ខែមករា ឆ្នាំ២០១៩

# មាតិកា


**១.ស្ថានភាពទូទៅ** ........ ១

**២.អំពីប្រជាសាស្ត្រ និង សេដ្ឋកិច្ចសង្គម** ........ ២

ក.ប្រជាពលរដ្ឋ ........ ២

ខ.មុខរបរ ........ ២

**៣.កន្លែងនេសាទសហគមន៍ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍** ........ ២

ក.ទីតាំង ........ ២

ខ. ដែននេសាទ ........ ៣

គ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស ........ ៤

ឃ.ធនធានជលផល ........ ៤

ឃ.១.ប្រភេទត្រី ........ ៤

ឃ.២.ប្រភេទវារីសត្វ ........ ៤

ឃ.៣.ប្រភេទសត្វបក្សី ........ ៤

ឃ.៤.ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ ........ ៤

**៤.ការធ្វើនេសាទ** ........ ៤

ក.អ្នកនេសាទ ........ ៤

ខ.ឧបករណ៍នេសាទ ........ ៤

គ.ប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ ........ ៦

**៥.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍** ........ ៧

ក.ទស្សនវិស័យ ........ ៧

ខ. គោលបំណងរួម ........ ៧

គ.គោលបំណងជាក់លាក់ ........ ៧

ឃ.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ........ ៧

ឃ.១.ធនធានជលផល និងអេកូឡូស៊ី ........ ៧

ឃ.១.១.ផែនការប្រើប្រាស់ឧបករណ៍នេសាទ ........ ៧

ឃ.១.២.ផែនការបោះបង្គោលព្រំប្រទល់សហគមន៍ និងផ្ទាំងប៉ាណូផែនទីសហគមន៍នេសាទ ........ ៨

ឃ.១.៣ ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស ........ ៨

ឃ.១.៤ ផែនការគ្រប់គ្រងព្រៃលិចទឹក ........ ៩

ឃ.២.ការគាំទ្រជីវភាពប្រជាពលរដ្ឋ ........ ៩

ឃ.២.១. ផែនការមុខរបរបង្កើនប្រាក់ចំណូល ........ ៩

ឃ.២.២.ផែនការអភិវឌ្ឍន៍វារីវប្បកម្ម ........ ១០

ឃ.២.៣. ផែនការសេវាសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច ........ ១០

ឃ.២.៤.ផែនការបង្ការ និងបន្សាំការប្រែប្រួលអាកាសធាតុ ........ ១១
ឃ.៣. ការងារគ្រប់គ្រង........ ១១
ឃ.៣.១. ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស ........ ១១
ឃ.៣.២.ផែនការពង្រឹងគណៈកម្មការសហគមន៍នេសាទ ........ ១២
ឃ.៣.៣. ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ ........ ១២
ឃ.៣.៤. ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ........ ១៣
ឃ.៣.៥. ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ ........ ១៣
ង.ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ........ ១៤
ការតាមដាន ត្រួពិនិត្យ និងវាយតម្លៃ ត្រូវបានរៀបចំដូចខាងក្រោម៖........ ១៤
ច.យុទ្ធសាស្រ្ត ........ ១៤
**តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍កោះឈើទាលតូច រយៈពេល៣ឆ្នាំ (២០២០ ដល់ ២០២២)** ........ ១៥
**តារាងកម្មវិធីការងាររយៈពេល៣ឆ្នាំ**(២០២០ - ២០២២) ........ ២១

# ផែនការគ្រប់គ្រង
# កន្លែងនេសាទសហគមន៍

## ១.ស្ថានភាពទូទៅ

សហគមន៍នេសាទកោះឈើទាលតូច ត្រូវបានបង្កើតឡើងដោយមហាសន្និបាតកំណើតដំបូងនៅឆ្នាំ២០០០ និងបានចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍លើកទី២ នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៨ រយៈពេល៣ឆ្នាំ គឺចាប់ពីថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៨ ដល់ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២១។សហគមន៍នេសាទនេះ មានទីតាំងស្ថិតនៅក្នុងភូមិកោះឈើទាលតូច ឃុំព្រះរំកិល ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង ដែលមានសមាជិកសរុបចំនួន៣៩៥នាក់ ស្រីចំនួន១៤៩នាក់ ស្មើនឹង១១៦គ្រួសារ និងមានគណៈកម្មការចំនួន០៧នាក់ ស្រីចំនួន០៣នាក់។ សហគមន៍នេសាទកោះឈើទាលតូច ត្រូវបានចុះបញ្ជីទទួលស្គាល់ជាផ្លូវការដោយប្រកាសលេខ ៦២៨ ប្រក.កសក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១១ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

បន្ទាប់ពីបានបោះឆ្នោតជ្រើសរើសគណៈកម្មការរួចមកសហគមន៍នេសាទនេះ បានអនុវត្តសកម្មភាពសំខាន់ៗមានដូចជាការរៀបចំបញ្ជីឈ្មោះ និងរចនាសម្ព័ន្ធរបស់គណៈកម្មការសហគមន៍នេសាទ ធ្វើបច្ចុប្បន្នភាព និងរៀបចំបញ្ជីឈ្មោះសមាជិក លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ ចូលរួមកំណត់ព្រំប្រទល់កន្លែងនេសាទសហគមន៍ រៀបចំកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ រៀបចំក្រុមល្បាត ព្រមទាំងចូលរួមប្រជុំ វគ្គបណ្តុះបណ្តាល និងសិក្ខាសាលាផ្សេងៗ។ រហូតមកដល់បច្ចុប្បន្នសហគមន៍នេសាទមានការរីកចម្រើន ដោយទទួលបានភាពជោគជ័យក្នុងកាត់បន្ថយសកម្មភាពបទល្មើសនេសាទនានាដែលធ្វើឱ្យផលនេសាទមានការកើនឡើងគួរអោយកត់សម្គាល់។

ទន្ទឹមនឹងសមិទ្ធផលដែលសម្រេចបានដូចខាងលើ សហគមន៍នេសាទនៅជួបប្រទះបញ្ហាប្រឈមពាក់ព័ន្ធនឹងធនធានជលផលនិងអេកូឡូស៊ី ជីវភាពប្រជាពលរដ្ឋ និងការគ្រប់គ្រងគឺៈ

-បញ្ហាប្រឈមពាក់ព័ន្ធនឹងធនធានជលផល និងអេកូឡូស៊ី រួមមាន ការកាប់បំផ្លាញព្រៃលិចទឹកនាំឱ្យបាត់បង់ព្រៃលិចទឹកជាច្រើន ត្រីថយចុះគ្រប់ប្រភេទ ការនេសាទនៅរដូវត្រីពងកូន បាក់ច្រាំងមាត់ទន្លេ និងកំណើនអ្នកនេសាទ

-បញ្ហាប្រឈមពាក់ព័ន្ធនឹងជីវភាពប្រជាពលរដ្ឋ រួមមាន ប្រជាពលរដ្ឋខ្វះមុខរបរចិញ្ចឹមជីវិត កំណើនប្រជាពលរដ្ឋប្រជាជនចំណាកស្រុកច្រើន ខ្វះប្រភពទឹកធ្វើស្រែ ខ្វះចំណេះដឹងនិងជំនាញបច្ចេកទេសចិញ្ចឹមសត្វ ដាំដំណាំ តម្លៃផលផលិតផលមិនស្ថិតស្ថេរ និងទីផ្សារនៅឆ្ងាយពីភូមិ

-បញ្ហាប្រឈមពាក់ព័ន្ធនឹងការគ្រប់គ្រង រួមមាន ការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ (ប្រើប្រាស់ឧបករណ៍ឆក់ ប្រើសារជាតិពុល និងដាក់ដាយ) ប្រជាពលរដ្ឋមិនហ៊ានរាយការណ៍ពេលឃើញបទល្មើស កិច្ចសហការជាមួយអាជ្ញាធរពាក់ព័ន្ធមិនទាន់រលូន មិនសូវមានការលើកទឹកចិត្តដល់គណកម្មការសហគ មន៍នេសាទ ប្រជាពលរដ្ឋមិនយល់ពីសារៈប្រយោជន៍នៃសហគមន៍នេសាទ ខ្វះមធ្យោបាយចុះល្បាត និងថវិកា គ្មានទីស្នាក់ការសហគមន៍សម្រាប់ប្រតិបត្តិការ គណៈកម្មការសហគមន៍នេសាទពុំទាន់ស្គាល់ពីតួនាទីរបស់ខ្លួន ហើយគណៈកម្មការសហគមន៍នេសាទ និងប្រជាជនមិនទាន់យល់ពីច្បាប់ស្តីពីជលផល លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ សមាជិកសហគមន៍យល់ថាការងាររបស់គណៈកម្មការជាតួនាទីរបស់បុរស ចំណែកស្ត្រីមានតួនាទីជាអ្នកថែទាំគ្រួសារ ធ្វើការងារផ្ទះ និងលក់ដូរប៉ុណ្ណោះ ហើយទោះបីមានស្ត្រីច្រើនចូលរួមក្នុងកិច្ចប្រជុំនានា ប៉ុន្តែការសម្រេចចិត្តរបស់ស្ត្រីនៅមានកម្រិត ។

## ២.អំពីប្រជាសាស្ត្រ និង សេដ្ឋកិច្ចសង្គម

### ក.ប្រជាពលរដ្ឋ

ចំនួនប្រជាពលរដ្ឋក្នុងភូមិកោះឈើទាលតូច សរុប៥៤៣នាក់ ស្រី២៥២នាក់ ស្មើ១២៥គ្រួសារ ចំនួនខ្នងផ្ទះ៨៤ខ្នងផ្ទះ ក្នុងនោះមានជនជាតិខ្មែរចំនួន១០០%។ ប្រជាពលរដ្ឋក្នុងសហគមន៍ជាអ្នកកាន់សាសនាព្រះពុទ្ធមាន១០០%។

ប្រជាពលរដ្ឋក្នុងភូមិកោះឈើទាលតូច មានស្ថានភាពដូចខាងក្រោម៖

- ចំនួនស្ត្រីជាមេគ្រួសារ/ស្ត្រីមេម៉ាយមាន១៥នាក់
- ចំនួនបុរសពោះម៉ាយមាន ០៣នាក់
- ចំនួនជនពិការក្នុងសហគមន៍នេសាទមាន០៥នាក់ ស្រី០៣នាក់
- ចំនួនចាស់ជរាមាន០៤នាក់ ស្ត្រី០២នាក់
- ចំនួនអ្នកមានជម្ងឺរាំរ៉ៃមាន០២នាក់
- កម្រិតសិក្សាអប់រំមាន អ្នកមិនចេះអក្សរមានចំនួន៧១នាក់ ស្រី២៩នាក់ កំរិតថ្នាក់បឋមសិក្សាចំនួន៦៧នាក់ ស្ត្រី២៧នាក់ កំរិតអនុវិទ្យាល័យចំនួន០១នាក់។

### ខ.មុខរបរ

មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងសហគមន៍នេះរួមមាន ៖

- អ្នកដែលមានមុខរបរនេសាទជាលក្ខណៈគ្រួសារចំនួន៧៥គ្រួសារ
- អ្នកធ្វើស្រែចំនួន៤៣គ្រួសារ ដែលមានទំហំដីចំនួនសរុប ២៥ ហិកតា
- ធ្វើចំការចំនួន៣២ គ្រួសារ ដែលមានទំហំដីចំនួនសរុប១៥ហិកតា (ស្រូវ.ពោត.ដំឡូង.ថ្នាំជក់...)
- ដាំបន្លែជាលក្ខណៈគ្រួសារ៩០គ្រួសារ ដែលមានទំហំសរុប ១ហិកតា
- ជាងផ្ទះ ០២គ្រួសារ
- លក់ដូរជាអាជីពចំនួន ០៦ គ្រួសារ
- ប្រមូលទិញផលនេសាទ ០៧គ្រួសារ
- ធ្វើកម្មករចំនួន ១៩គ្រួសារ
- ចិញ្ចឹមសត្វលក្ខណៈគ្រួសារ ១០៧ គ្រួសារ ស្មើ ៨៥%
- ជាងទូក ០២ គ្រួសារ
- ពេទ្យសត្វ ០១ គ្រួសារ
- ចំណាកស្រុកទៅក្រៅប្រទេស ២៥ នាក់ ស្ត្រី១៥នាក់
- កែច្នៃផលនេសាទជាលក្ខណៈគ្រួសារចំនួន១១០ គ្រួសារ ក្នុងនោះរួមមានប្រហុក ត្រីប្រៃ (មួយគ្រួសារអាចផលិតបានពី១០ គីឡូក្រាមទៅ ៦០គីឡូក្រាមក្នុង១ឆ្នាំ)។

## ៣.កន្លែងនេសាទសហគមន៍ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍

### ក.ទីតាំង

កន្លែងនេសាទសហគមន៍កោះឈើទាលតូច ជាដែននេសាទសាធារណៈរបស់រដ្ឋ។ កន្លែងនេសាទសហគមន៍កោះឈើទាលតូចមានទំហំ ៤៦៤ ហិកតា និងមានកំណត់និយាមកាដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង។

**មានព្រំប្រទល់៖**

- ខាងជើងទល់នឹង កោះឬស្សី ព្រំប្រទល់សហគមន៍ភូមិកោះឈើទាលធំ

- ខាងត្បូងទល់នឹង កន្ទុយកោះខនកែវ ព្រំប្រទល់សហគមន៍ភូមិរ៉ឺនសៀន
- ខាងកើតទល់នឹង ពាក់កណ្ដាលទន្លេព្រំប្រទល់សហគមន៍ភូមិអូររុន អូរស្វាយ និង កោះព្នៅ
- ខាងលិចទល់នឹង ខាងកើតកោះកក និងកោះខនខាំព្រំប្រទល់សហគមន៍ភូមិក្រឡាពាស។

**ខ. ដែននេសាទ**

កន្លែងសហគមន៍នេសាទកោះឈើទាលតូច មានវិសាលភាពនៅក្នុងទន្លេមេគង្គ ហើយមានប្រឡាយចំនួន០៥ កោះចំនួន១០ និងអន្លង់ចំនួន០៥។

**ខ.១.ទន្លេ**

| ឈ្មោះទន្លេ | ប្រវែង (ម៉ែត្រ) | រដូវនេសាទ |
|---|---|---|
| ទន្លេមេគង្គ | ៩.៨០០ | ពេញមួយឆ្នាំ |

**ខ.២.ប្រឡាយ**

| ឈ្មោះអូរ | ប្រវែង (ម៉ែត្រ) | រដូវនេសាទ |
|---|---|---|
| ប្រឡាយឈើទាល | ២៥ | នេសាទមិនបាន |
| ប្រឡាយដំបង | ៣០ | នេសាទបានក្នុងរដូវវស្សា |
| ប្រឡាយល្វា | ៥០០ | នេសាទបានក្នុងរដូវវស្សា |
| ប្រឡាយតាពៃ | ២០ | នេសាទបានក្នុងរដូវវស្សា |
| ប្រឡាយឬស្សី | ២៥ | នេសាទបានក្នុងរដូវវស្សា |

**ខ.៣.កោះ**

| ឈ្មោះកោះ | ទទឹង និងបណ្ដោយ (ម៉ែត្រ) | ទំហំសរុប (ហិកតា) |
|---|---|---|
| កោះទន្សាយ | ២៥ × ១០ | ០,០២៥ |
| កោះឬស្សីធំ | ៣០០ × ៧០ | ២,១ |
| កោះឬស្សីតូច | ២០០ × ៥០ | ១ |
| កោះកាន់ចៅ | ២៣០ × ៧០ | ១,៦១ |
| កោះឱឡឹក | ១០០ × ២០០ | ២ |
| កោះកក | ១.០០០ × ៣០០ | ៣០ |
| កោះឬស្សីក្រោម | ១.០០០ × ២០០ | ២០ |
| កោះខនកែវ | ១.៥០០ × ៣០០ | ៤៥ |
| កោះជ្រូក | ១០០ × ៥០ | ០,៥ |
| កោះតាអាន | ៥០ × ៥០ | ០,២៥ |

ខ.៤.អន្លង់

| ឈ្មោះអន្លង់ | ទទឹង និងបណ្តោយ (ម៉ែត្រ) | សរុប (ម៉ែត្រក្រឡា) | ជម្រៅ | |
|---|---|---|---|---|
| | | | រដូវវស្សា (ម៉ែត្រ) | រដូវវស្សា (ម៉ែត្រ) |
| អន្លង់កោះទន្សាយ | ប: ១៥០ x ទ: ៧០ | ១០.៥០០ | ៣៣ | ២៥ |
| អន្លង់ខ្មែក | ប: ៧០ x ទ:៧០ | ៤.៩០០ | ១៤ | ០៦ |
| អន្លង់ក្រមួន | ប: ៥០ x ទ:៣០ | ១.៥០០ | ១៥ | ០៧ |
| អន្លង់រមាស | ប: ៣០០ x ទ:៣០ | ៩.០០០ | ១៥ | ០៧ |
| អន្លង់ព្រះសាខន | ប: ២០០ x ទ:១០០ | ២០.០០០ | ៣៨ | ៣០ |

**គ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស**

តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្សមានចំនួន១ អន្លង់ គឺអន្លង់ព្រះសាខន តាមការសម្រេចរបស់មហាសន្និបាត (មាន៥ភូមិចូលរួមគឺ ភូមិឈើទាលតូច អូរស្វាយ អូររុន កោះព្នៅ និងភូមិក្រឡាពាស) ។

| ឈ្មោះអន្លង់ | ទទឹង និងបណ្តោយ( ម៉ែត្រ) | សរុប (ម៉ែត្រក្រឡា) | ជម្រៅ | |
|---|---|---|---|---|
| | | | រដូវវស្សា (ម៉ែត្រ) | រដូវប្រាំង (ម៉ែត្រ) |
| អន្លង់ព្រះសាខន | ប: ២០០ x ទ:១០០ | ២០.០០០ | ៣៨ | ៣០ |

**ឃ.ធនធានជលផល**

**ឃ.១.ប្រភេទត្រី៖**

ត្រីរ៉ស់ ឆ្តោរ រៀល ស្លាត ឆ្លាំង ក្រម៉ម អណ្តែង ច្រវ៉ា កំភ្លាញ ឆ្ពួញ ខ្ទាន់ ឆ្ពិន ច្រកែង កន្ធ្រប់ ត្រីដំរី កញ្ចុះ ក្រុះ កញ្ជ្រូក ទ្រនេល សណ្តាយ ក្រាយ ព្រលូង ត្រីស្លឹកឫស្សី ត្រីខ្នីង ត្រីខ្យា ត្រីកេះ ឆ្តោក ត្រីកែ ត្រីក្រសក់ ត្រីខ្មែក ត្រីថ្ម ត្រីចិន ត្រីបបែល ត្រីពោ ត្រីចេកទុំ ត្រីស្លាំងហាយ ត្រីក្របី ត្រីឫស្សីចេក ត្រីខ្យាថ្ម ត្រីប៉ាស៊ីអ៊ី ត្រីប៉ាវ៉ា ត្រីអាចម៍កុក....។

**ឃ.២.ប្រភេទវារីសត្វ៖**

ក្តាម ខ្យង ខ្ចៅ គ្រុម លៀស ពស់ កំពិស កង្កែប ហ៊ីង គីង្គក់...។

**ឃ.៣.ប្រភេទសត្វបក្សី**

កុកស កុកក្រក មាន់ទឹក ប្រវឹក ទាព្រៃ រនាលខ្យង ក្អែកទឹក ក្អែកគោក...។

**ឃ.៤.ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ៖**

ដើមក្រែង ដើមអញ្ចាង ដើមរាំចេក ដើមអណ្តែង ដើមក្រស់ ដើមរាំង ដើមល្វា ដើមឆ្នាទឹក ដើមក្តុល ដើមជ្រៃ....។

**៤.ការធ្វើនេសាទ**

**ក.អ្នកនេសាទ**

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន៦៣គ្រួសារ ស្មើ១២៦នាក់ ស្រី៦០នាក់
- អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទនៅក្នុងសហគមន៍មានចំនួន៩គ្រួសារ ស្មើ៩នាក់
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍ ចំនួន៥០គ្រួសារស្មើ៥០នាក់ស្រី២០។

**ខ.ឧបករណ៍នេសាទ**

ឧបករណ៍នេសាទ និងទូកការណូតរបស់សមាជិកសហគមន៍នេសាទ អ្នកមិនចូលជាសមាជិក និងអ្នកនេសាទមកពីក្រៅសហគមន៍៖

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន | | | ទំហំ / ប្រវែង | | | រដូវប្រើប្រាស់ឧបករណ៍ |
|---|---|---|---|---|---|---|---|---|
| | | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ | |
| មង | ម៉ែត្រ | ១១០គ្រួសារ× ១០០ម = ១១.០០០ម | ៩គ្រួសារ× ១០០ម= ៩០០ម | ១៥គ្រួសារ× ២០០ម =៣.០០០ម | ក្រឡា២-១២ ស.មជម្រៅ ៣-៥ម | ក្រឡា២-១២ ស.មជម្រៅ ៣-៥ម | ក្រឡា២-១២ ស.មជម្រៅ ៣-៥ម | ពេញមួយឆ្នាំ |
| សំណាញ់ | វង់ | ១១៦គ្រួសារ× ២វង់=២៣២ វង់ | ៩គ្រួសារ× ១វង់=៩វង់ | គ្មាន | ក្រឡា១,៥-៧ស.ម សំរុង៣,៥-៥,៥ម | ក្រឡា១,៥-៧ស.ម សំរុង៣,៥-៥,៥ម | គ្មាន | ប្រាំង |
| សន្ទូច | ផ្លែ | ១១០គ្រួសារ× ១០០ផ្លែ = ១១.០០០ផ្លែ | ២គ្រួសារ× ១០០ផ្លែ =២០០ផ្លែ | ១៥គ្រួសារ× ៥០ផ្លែ =៧៥០ផ្លែ | ផ្លែលេខ ១២-៥ | ផ្លែលេខ ១២-៥ | ផ្លែលេខ ១២-៥ | ពេញមួយឆ្នាំ |
| លប | គ្រឿង | ៥០គ្រួសារ × ៣គ្រឿង =១៥០គ្រឿង | ៩គ្រួសារ × ៣គ្រឿង = ២៧គ្រឿង | គ្មាន | មុខកាត់ ០,៣០ម ប្រវែង ១ម | មុខកាត់ ០,៣០ម ប្រវែង ១ម | គ្មាន | វស្សា |
| ចាន់ | គ្រឿង | ៥០គ្រួសារ×៥ គ្រឿង=២៥០ គ្រឿង | ៩គ្រួសារ× ៥គ្រឿង = ៤៥គ្រឿង | គ្មាន | មុខកាត់ ៤០ស.ម ប្រវែង១.៣ម | មុខកាត់ ៤០ស.ម ប្រវែង១.៣ម | គ្មាន | វស្សា |
| សៃយឺន | គ្រឿង | ១១០គ្រួសារ× ១គ្រឿង =១១០គ្រឿង | ៩គ្រួសារ× ១គ្រឿង = ៩គ្រឿង | គ្មាន | មុខកាត់ ៥០ស.ម ប្រវែង២,៥ម | មុខកាត់ ៥០ស.ម ប្រវែង២,៥ម | គ្មាន | វស្សា |
| តុំ | គ្រឿង | ៣០គ្រួសារ×២ =៦០គ្រឿង | គ្មាន | គ្មាន | មុខកាត់ ៣០ស.ម | គ្មាន | គ្មាន | វស្សា |
| ទ្រូ | គ្រឿង | ៤៥គ្រួសារ×២ =៩០គ្រឿង | ៣គ្រួសារ× ២=៦គ្រឿង | គ្មាន | មុខកាត់៤០ ស.ម ប្រវែង ១,២ម | មុខកាត់៤០ ស.ម ប្រវែង ១,២ម | គ្មាន | វស្សា |
| ឈ្នាងត្រាំ | គ្រឿង | ៥០គ្រួសារ× ១០ =៥០០ គ្រឿង | ៥គ្រួសារ×៥= ២៥គ្រឿង | គ្មាន | មុខកាត់ ៧០ស.ម ប្រវែង ៧០ ស.ម | មុខកាត់ ៧០ស.ម ប្រវែង ៧០ ស.ម | គ្មាន | វស្សា |
| ឈ្នាងជញ្ជាត់ | គ្រឿង | ២០គ្រួសារ×១ =២០គ្រឿង | គ្មាន | គ្មាន | មុខកាត់៨០ ស.ម | គ្មាន | គ្មាន | វស្សា |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| អង្រុត | គ្រឿង | ៨០គ្រួសារ×១ =៨០គ្រឿង | គ្មាន | គ្មាន | មុខកាត់ ៥០ ស.ម | គ្មាន | គ្មាន | វស្សា |
| ស្នាង | គ្រឿង | ៥០គ្រួសារ×៥ =២៥០គ្រឿង | ៩គ្រួសារ× ៥=៤៥គ្រឿង | គ្មាន | មុខកាត់១ម ប្រវែង៥ម | មុខកាត់១ម ប្រវែង៥ម | គ្មាន | ពេញមួយ ឆ្នាំ |
| ស្នូរ | គ្រឿង | ១១០គ្រួសារ×១ =១១០គ្រឿង | ៩គ្រួសារ× ១=៩គ្រឿង | គ្មាន | ប្រវែង ៣ម | ប្រវែង ៣ម | គ្មាន | ពេញមួយ ឆ្នាំ |

ប្រភេទទូកកាណូត

| ប្រភេទកាណូត | ចំនួន (គ្រឿង) | | | ចំណុះ (គីឡូក្រាម) | | | កំលាំង (សេះ) | | |
|---|---|---|---|---|---|---|---|---|---|
| | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ |
| ទូកអរជាប់ម៉ាស៊ីន HONDA / HINOTA | ១១៦ | ៩ | ៥០ | ១០០-៥០០ | ១០០-៥០០ | ៣០០-៥០០ | ៨-១៣ | ១៣ | ១៣ |
| ទូកម៉ាស៊ីនដឹកទំនិញ | ៤ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ |
| ទូកអុំ ចែវ | ៣ | ០ | ០ | ១០០-៣០០ | ០ | ០ | ០ | ០ | ០ |

គ.ប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមក្នុង១គ្រួសារ | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រី | ៧៤១,១៤ | ៩១៩,៩១ | ១.៦៦១,០ |
| សរុប | | | **១.៦៦១,០** |



## ៥.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### ក.ទស្សនៈវិស័យ

សហគមន៍នេសាទកោះឈើទាលតូច មានទស្សនៈវិស័យរួមចំណែកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលប្រកបដោយសមធម៌ និងចីរភាពដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ

### ខ. គោលបំណងរួម

ដើម្បីសម្រេចបាននូវទស្សនៈវិស័យខាងលើ សហគមន៍នេសាទ មានគោលបំណងរួមដូចខាងក្រោម៖

- ធ្វើឱ្យត្រីមានការកើនឡើង
- បង្កើនប្រាក់ចំណូលដល់សមាជិកសហគមន៍នេសាទ
- បទល្មើសនេសាទមានការថយចុះ ។

### គ.គោលបំណងជាក់លាក់

- ចូលរួមគ្រប់គ្រងដែននេសាទទឹកសាប កន្លែងនេសាទគ្រួសារដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណី ឬសហគមន៍ធ្វើនេសាទ កន្លែងនេសាទបំរុង ទំនាបលិចទឹក ក្នុងរដូវជំឡើង នាទីព្រៃលិចទឹក
- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តភាព និងធានាការបែងចែកផលប្រយោជន៍ ធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌
- ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍ តាមរយៈការអភិវឌ្ឍន៍ចម្រុះដោយមានការចូលរួម
- ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ ហើយនិងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់លើធនធានធម្មជាតិ។

### ឃ.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### ឃ.១.ធនធានជលផល និងអេកូឡូស៊ី

### ឃ.១.១.ផែនការប្រើប្រាស់ឧបករណ៍នេសាទ

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍គឺគិតគូរអំពីដែននេសាទ ប្រភេទឧបករណ៍នេសាទ ទំហំ ប្រវែង ចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ ត្រូវបានរៀបចំដូចខាងក្រោម៖

| ឈ្មោះទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | | | ផ្សេងៗ |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន | |
| ក្នុងទន្លេមេគង្គកន្លែងនេសាទសហគមន៍កោះឈើទាលតូច | នេសាទពេញ១ឆ្នាំជាលក្ខណៈគ្រួសារ | មង | ក្រឡា២-១២ស.មជម្រៅ៣-៥ម | ១០០ម៉ែត្រ/គ្រួសារ | |
| | | សំណាញ់ | ក្រឡា១,៥-៧ស.ម សំរុង៣,៥-៥,៥ម | ២វង់/គ្រួសារ | |
| | | សន្ទូច | ផ្លែលេខ១២-៥ | ១០០ផ្លែ/គ្រួសារ | |
| | | លប | មុខកាត់ ០,៣០ម ប្រវែង ១ម | ៣គ្រឿង/គ្រួសារ | |
| | | ចាន់ | មុខកាត់៤០ស.មប្រវែង១,៣ម | ៥គ្រឿង/គ្រួសារ | |
| | | សៃយ៉ឺន | មុខកាត់ ៥០ស.ម ប្រវែង២,៥ម | ១គ្រឿង/គ្រួសារ | |
| | | ឈ្នាងត្រាំ | មុខកាត់៧០ស.ម ប្រវែង ៧០ស.ម | ១០គ្រឿង/គ្រួសារ | |
| -ប្រឡាយឈើទាល<br>-ប្រឡាយដំបង<br>-ប្រឡាយ ល្វា<br>-ប្រឡាយតាពៃ និង | ខែ៨ - ខែ១២ | មង | ក្រឡា២-១២ស.មជម្រៅ៣-៥ម | ១០០ម៉ែត្រ/គ្រួសារ | |
| | | សំណាញ់ | ក្រឡា១,៥-៧ស.ម សំរុង៣,៥-៥,៥ម | ២វង់/គ្រួសារ | |
| | | សន្ទូច | ផ្លែលេខ១២-៥ | ១០០ផ្លែ/គ្រួសារ | |
| | | លប | មុខកាត់ ០,៣០ម ប្រវែង ១ម | ៣គ្រឿង/គ្រួសារ | |

| | | | | |
|---|---|---|---|---|
| -ប្រឡាយឫស្សី | | ចាន់ | មុខកាត់៤០ស.មប្រវែង១,៣ម | ៥គ្រឿង/គ្រួសារ |
| | | សៃយ៉ឺន | មុខកាត់ ៥០ស.ម ប្រវែង២,៥ម | ១គ្រឿង/គ្រួសារ |
| | | តុំ | មុខកាត់៣០ស.ម | ២គ្រឿង/គ្រួសារ |
| | | ទ្រូ | មុខកាត់៤០ស.ម ប្រវែង ១,២ម | ២គ្រឿង/គ្រួសារ |
| | | ឈ្នាងញាត់ | មុខកាត់៨០ស.ម | ១គ្រឿង/គ្រួសារ |
| | | អង្រុត | មុខកាត់ ៥០ ស.ម | ១គ្រឿង/គ្រួសារ |
| | | ស្នាង | មុខកាត់១ម ប្រវែង៥ម | ១០គ្រឿង/គ្រួសារ |
| | | ស្នរ | ប្រវែង ៣ម | ១គ្រឿង/គ្រួសារ |

### ឃ.១.២.ផែនការបោះបង្គោលព្រំប្រទល់សហគមន៍ និងផ្ទាំងប៉ាណូផែនទីសហគមន៍នេសាទ

ផែនការបោះបង្គោលព្រំប្រទល់ និងផ្ទាំងប៉ាណូផែនទីសហគមន៍នេសាទ ត្រូវបានរៀបចំដូចខាងក្រោម៖

| ឈ្មោះដែននេសាទ | ទំហំ/ចំនួន | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | អ្នកទទួលខុសត្រូវ | ពេលវេលា | |
|---|---|---|---|---|---|---|
| | | | | | ចាប់ផ្តើម | បញ្ចប់ |
| កន្លែងនេសាទសហគមន៍កោះឈើទាល តូច | បង្គោលព្រំធ្វើពីស៊ីម៉ងត៍ចំនួន៦បង្គោល | - ផ្សព្វផ្សាយជាសាធារណៈ<br>- ផលិតបង្គោលព្រំ<br>- រៀបចំក្រុមចុះបោះបង្គោលព្រំ | ៦០០ | គណៈកម្មការសមាជិកមេភូមិ | ២០២០ | ២០២២ |
| | ផ្ទាំងប៉ាណូផែនទីធ្វើពីដែក៣ផ្ទាំង | - ផលិតផ្ទាំងប៉ាណូផែនទី<br>- ចុះបោះផ្ទាំងប៉ាណូផែនទី | ៥០០ | គណៈកម្មការសមាជិកមេភូមិ | ២០២០ | ២០២២ |
| | ស្លាកអប់រំ៣០ | ចុះបោះស្លាកក្នុងសហគមន៍ | ១២០ | គណៈកម្មការ | ២០២០ | ២០២២ |

### ឃ.១.៣ ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស

ផែនការរៀបចំកន្លែងអភិរក្ស ត្រូវបានរៀបចំដូចខាងក្រោម៖

| ឈ្មោះ | ទំហំហិកតា | ប្រភេទនៃការអភិរក្ស | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|---|---|
| អន្លង់ព្រះសាខន | ២ | - ត្រីមេពូជ<br>- សត្វស្លាប<br>- ព្រៃលិចទឹកគ្រប់ | - ផ្សព្វផ្សាយពីកន្លែងអភិរក្សដល់សមាជិកសហគមន៍ឱ្យបានទូលំទូលាយចំនួន ២ដង/១ឆ្នាំ<br>- បោះទង់សំគាល់ព្រំតំបន់អភិរក្ស<br>- ដាក់ស្លាកតាមអន្លង់អភិរក្ស ៣០<br>-ដាក់ប៉ាណូផែនទីអន្លង់អភិរក្ស១ស្លាក<br>- ចុះល្បាតការពារជាប្រចាំ | ៣០០ | ២០២០ | ២០២២ |

### ឃ.១.៤ ផែនការគ្រប់គ្រងព្រៃលិចទឹក

ផែនការគ្រប់គ្រងព្រៃលិចទឹក ត្រូវបានរៀបចំដូចខាងក្រោម៖

| ឈ្មោះ/ទីតាំង | ទំហំ (ហិកតា) | ប្រភេទកូនឈើត្រូវការពារ | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្ដើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|---|---|
| នៅក្នុងកន្លែងនេសាទសហគមន៍កោះឈើទាលតូច | ៤៣ | ព្រៃលិចទឹកចម្រុះ | - ផ្សព្វផ្សាយឱ្យបានទូលំទូលាយពីសារៈប្រយោជន៍ព្រៃលិចទឹក<br>- ដាក់ស្លាកហាមកាប់ព្រៃលិចទឹក<br>- ថែរក្សា ការពារព្រៃលិចទឹកចម្រុះ<br>- ចុះល្បាតការពារជាប្រចាំ | ១.២០០ | ២០២០ | ២០២២ |

### ឃ.២.ការគាំទ្រជីវភាពប្រជាពលរដ្ឋ

### ឃ.២.១. ផែនការមុខរបរបង្កើនប្រាក់ចំណូល

ផែនការមុខរបរបង្កើនប្រាក់ចំណូល ត្រូវបានរៀបចំដូចខាងក្រោម៖

| ប្រភេទមុខរបរ | សកម្មភាព | ប្រភេទ/បរិមាណ | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្ដើម | ថ្ងៃខែឆ្នាំប្រមូលផ |
|---|---|---|---|---|---|
| ចិញ្ចឹមមាន់តាមបច្ចេកទេសជាលក្ខណៈគ្រួសារ ចំនួន ៣០គ្រួសារ | - ជ្រើសរើសគ្រួសារកសិករស្ម័គ្រចិត្ត<br>- បណ្ដុះបណ្ដាលចិញ្ចឹមមាន់តាមបច្ចេកទេសជាក្ខណៈគ្រួសារ<br>- អនុវត្តជាក់ស្តែងជាមួយគ្រួសារកសិករ ធ្វើទ្រុង ផ្ដល់ពូជចិញ្ចឹម<br>- តាមដានត្រួតពិនិត្យជាប្រចាំ | ពូជក្នុងស្រុក ១គ្រួសារទទួលបានមាន់៥ក្បាល សរុប៧៥ក្បាល | ១.៦០០ | ២០២០ | ២០២២ |
| ចិញ្ចឹមជ្រូកតាមបច្ចេកទេសជាលក្ខណៈគ្រួសារ ចំនួន ៣០គ្រួសារ | - ប្រជុំផ្សព្វផ្សាយជ្រើសរើសកសិករ<br>- រៀបចំទ្រុងសម្រាប់ចិញ្ចឹម<br>- បណ្ដុះបណ្ដាលបច្ចេកទេសចិញ្ចឹម<br>- រកទិញពូជ និងដាក់ពូជចិញ្ចឹម<br>- តាមដានត្រួតពិនិត្យការថែទាំ | ពូជក្នុងស្រុក | ២.៩០០ | ២០២០ | ២០២២ |
| ចិញ្ចឹមគោតាមបច្ចេកទេសជាលក្ខណៈគ្រួសារ ចំនួន៤០គ្រួសារ | - ជ្រើសរើសគ្រួសារកសិករស្ម័គ្រចិត្ត<br>- បង្កើតគោលការណ៍<br>- ផ្ដល់ពូជ<br>- ត្រួតពិនិត្យតាមដាន | ពូជក្នុងស្រុក | ១២.០០០ | ២០២០ | ២០២២ |
| ចិញ្ចឹមក្របីតាមបច្ចេកទេសលក្ខណៈគ្រួសារចំនួន ៣០ គ្រួសារ | - ជ្រើសរើសគ្រួសារកសិករស្ម័គ្រចិត្ត<br>- បង្កើតគោលការណ៍<br>- ផ្ដល់ពូជ<br>- ត្រួតពិនិត្យតាមដាន | ពូជក្នុងស្រុក | ៩.០០០ | ២០២០ | ២០២៤ |

| | | | | | |
|---|---|---|---|---|---|
| ចិញ្ចឹមចង្រិតតាមបច្ចេកទេសចំនួន១៥គ្រួសារ | - ជ្រើសរើសគ្រួសារកសិករស្ម័គ្រចិត្ត<br>- បង្កើតគោលការណ៍<br>- ផ្តល់ពូជ<br>- ត្រួតពិនិត្យតាមដាន | ពូជក្នុងស្រុក | ៤.៥០០ | ២០២០ | ២០២២ |
| បច្ចេកទេសបណ្តុះសណ្តែកចំនួន១៥គ្រួសារ | - ជ្រើសរើសគ្រួសារកសិករស្ម័គ្រចិត្ត<br>- បង្កើតគោលការណ៍<br>- ត្រួតពិនិត្យតាមដាន | ពូជក្នុងស្រុក | ៤,៥០០ | ២០២០ | ២០២២ |
| ដាំបន្លែតាមបច្ចេកទេសកសិកម្មវ័យឆ្លាតចំនួន១៥គ្រួសារ | - ប្រជុំផ្សព្វផ្សាយជ្រើសរើសកសិករ<br>- បណ្តុះបណ្តាលបច្ចេកទេសដាំ<br>- ផ្តល់គ្រាប់ពូជ រៀបចំដាំ<br>- តាមដានត្រួតពិនិត្យការថែទាំ | គ្រាប់ពូជបន្លែ(ស្ពៃ ត្រកួន ត្រសក់ សណ្តែក គ្រប់) | ៣.០០០ | ២០២០ | ២០២២ |

### ឃ.២.២.ផែនការអភិវឌ្ឍន៍វារីវប្បកម្ម

ផែនការអភិវឌ្ឍន៍វារីវប្បកម្ម ត្រូវបានរៀបចំដូចខាងក្រោម៖

| ប្រភេទវារីវប្បកម្ម | សកម្មភាព | ចំនួន | បរិមាណកូនត្រី | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | ខែ/ឆ្នាំចាប់ផ្តើម | ខែ/ឆ្នាំបញ្ច |
|---|---|---|---|---|---|---|
| ចិញ្ចឹមត្រីអណ្តែងក្នុងស្រះតាមបច្ចេកទេសលក្ខណៈគ្រួសារ (៥គ្រួសារ/ឆ្នាំ) | - ប្រជុំផ្សព្វផ្សាយជ្រើសរើសកសិករ<br>- រៀបចំស្រះ ដាក់កូនត្រី<br>- បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រី<br>- ត្រួតពិនិត្យ ធ្វើសំណាក | ៥ស្រះ ទំហំ ៥ម×១០ម | ១.៥០០ ក្បាល/៥ គ្រួសារ | ៩.០០០ | ២០២០ | ២០២២ |

### ឃ.២.៣. ផែនការសេវាសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច

ផែនការសេវាសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច ត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | ប៉ាន់ប្រមាណថវិកា(ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ច |
|---|---|---|---|
| សាងសង់លូកាត់ផ្លូវចំនួន៥កន្លែង | ១០.០០០ | ២០២០ | ២០២២ |
| សាងសង់បង្គន់អនាម័យចំនួន៥០គ្រួសារ | ៥.០០០ | ២០២០ | ២០២២ |
| ជួសជុលអណ្តូងស្នប់៥អណ្តូង | ៥.០០០ | ២០២០ | ២០២២ |
| ជួសជុលផ្លូវដីស (១៥០០ម) ១ខ្សែ | ១០.០០០ | ២០២០ | ២០២២ |
| រៀបចំប្រព័ន្ធទឹកស្អាតក្នុងសហគមន៍១កន្លែង | ១០.០០០ | ២០២០ | ២០២២ |
| ផ្តល់ធុងចម្រោះទឹក៥០ ធុង | ២.៥០០ | ២០២០ | ២០២២ |

### ឃ.២.៤.ផែនការបង្ការ និងបន្សាំការប្រែប្រួលអាកាសធាតុ

ផែនការបង្ការ និងបន្សាំការប្រែប្រួលអាកាសធាតុ ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| ប្រភេទ | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្ដើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|
| ផែនការបង្ការ និងបន្សាំភាពធន់និងការប្រែប្រួលអាកាសធាតុ | ផ្សព្វផ្សាយពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងការបង្ការ | ១០០ | ២០២០ | ២០២២ |
| | រៀបចំបង្គោលវាស់កម្ពស់ទឹក | ២០០ | ២០២០ | ២០២២ |
| | កំណត់ រៀបចំទីទួលសុវត្ថិភាព | ១០០ | ២០២០ | ២០២២ |
| | ពង្រឹងក្រុមទ្រទ្រង់គ្រោះមហន្តរាយភូមិ | ១០០ | ២០២០ | ២០២២ |
| | ផ្តល់វគ្គបណ្តុះបណ្តាលស្តីពីការបន្សាំការប្រែប្រួលអាកាសធាតុ | ១០០ | ២០២០ | ២០២២ |
| | ចងក្រងបណ្តាញក្រុមទ្រទ្រង់គ្រោះមហន្តរាយតាមភូមិ | ១០០ | ២០២០ | ២០២២ |

### ឃ.៣. ការងារគ្រប់គ្រង

### ឃ.៣.១. ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស

ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស ត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | តម្រូវការសម្ភារ | ចំនួន | ថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្ដើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|---|
| សហគមន៍ចុះល្បាតដោយខ្លួនឯង | | ៣ដង/១ខែ | ៥.២០០ | ២០២០ | ២០២២ |
| ចុះល្បាតដោយសហការជាមួយអាជ្ញាធរមូលដ្ឋានដើម្បីទប់ស្កាត់បទល្មើសមកពីក្រៅ | | ២ដង/១ខែ | | ២០២០ | ២០២២ |
| ប្រេងសម្រាប់ល្បាត | | ៥០លីត្រ/ខែ | | ២០២០ | ២០២២ |
| សេវាជួសជុលនិងថែទាំទូក និងម៉ាស៊ីន | | ២ ដង/ឆ្នាំ | | ២០២០ | ២០២២ |
| ផ្តល់សម្ភារៈល្បាត (១ ឈុត) | អាវពោង | ៧ អាវ | ១.០០០ | ២០២០ | ២០២២ |
| | អាវភ្លៀង | ៧ អាវ | | | |
| | គោមបំភ្លឺពាក់ក្បាល | ៧ គោម | | | |
| | វិទ្យុទាក់ទង | ៤ គ្រឿង | | | |
| | កែវយឹត | ២ គ្រឿង | | | |
| | ម៉ាស៊ីនថត | ១ គ្រឿង | | | |
| | អង្រឹង | ៧ អង្រឹង | | | |
| | តង់គ្របទូក ៤ម x ៦ម | ៣ តង់ | | | |
| | សម្ភារត្រួតពិនិត្យទឹក | ១ កំប្លេ | | | |

| | | | | | |
|---|---|---|---|---|---|
| | ស្លាបចក្រ | ៦ គ្រឿង | | | |
| | សោរសម្រាប់ជួសជុលទូក | ៣ សម្រាប់ | | | |
| | សោរច្រវាក់ចាក់ទូក | ៣ សោរ | | | |
| ទិញទូកស្ទាច់ម៉ាស៊ីន (១៣-១៨ សេះ) | | ៣ គ្រឿង | ៣.០០០ | ២០២០ | ២០២២ |
| សាងសង់ទីស្នាក់ការសហគមន៍ | ដីមានស្រាប់ (មេភូមិ) | ១ កន្លែង | ៣.០០០ | ២០២០ | ២០២២ |

### ឃ.៣.២.ផែនការពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍នេសាទ

ផែនការពង្រឹងគណៈកម្មការសហគមន៍នេសាទ ត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | ចំនួន | ប៉ាន់ប្រមាណតម្លៃ (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្ដើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|
| រៀបចំប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍នេសាទ | ១២ដង/១ឆ្នាំ | ៣៤០ | ២០២០ | ២០២២ |
| ចូលរួមប្រជុំប្រចាំខែ ឬត្រីមាស ជាមួយក្រុមប្រឹក្សាឃុំ | ៦ដង/១ឆ្នាំ | ៣៤០ | | |
| បណ្ដុះបណ្ដាលការគ្រប់គ្រងថវិកា បញ្ជីស្នាម | ១ដង/១ឆ្នាំ | ២៥០ | | |
| បណ្ដុះបណ្ដាលសរសេរគម្រោងសំណើរខ្នាតតូច | ១ដង/១ឆ្នាំ | ២៥០ | | |
| បណ្ដុះបណ្ដាលការដោះស្រាយទំនាស់ វិធីសាស្ត្រចុះល្បាត | ១ដង/១ឆ្នាំ | ២៥០ | | |
| បណ្ដុះបណ្ដាលអំពីជំនាញសម្របសម្រួល | ១ដង/១ឆ្នាំ | ២៥០ | | |
| បណ្ដុះបណ្ដាលអំពីការរៀបចំផែនការ | ១ដង/១ឆ្នាំ | ២៥០ | | |
| បណ្ដុះបណ្ដាលអំពីច្បាប់ជលផល | ១ដង/១ឆ្នាំ | ២៥០ | | |
| បណ្ដុះបណ្ដាលភាពអ្នកដឹកនាំ | ១ដង/១ឆ្នាំ | ២០០ | | |
| បណ្ដុះបណ្ដាលច្បាប់ស្ដីពីតំបន់ការពារ | ១ដង/១ឆ្នាំ | ១៥០ | | |
| ទស្សនៈកិច្ចសិក្សាក្រៅខេត្ត | ១ដង/១ឆ្នាំ | ១.០០០ | | |

### ឃ.៣.៣. ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ

ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ ត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | ចំនួនដង | ប៉ាន់ប្រមាណតម្លៃ (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្ដើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|
| ផ្សព្វផ្សាយលក្ខន្តិកៈ និងបទបញ្ញាផ្ទៃក្នុងសហគមន៍ | ២ដង/ឆ្នាំ | ៦០០ | ២០២០ | ២០២២ |
| ផ្សព្វផ្សាយកិច្ចព្រមព្រៀងសហគមន៍នេសាទ | ២ដង/ឆ្នាំ | ៦០០ | ២០២០ | ២០២២ |
| ច្បាប់ជលផល និងបទដ្ឋានបច្ចេកទេសពាក់ព័ន្ធ | ២ដង/ឆ្នាំ | ៦០០ | ២០២០ | ២០២២ |
| ផ្សព្វផ្សាយច្បាប់ស្ដីពីតំបន់ការពារធនធានធម្មជាតិ | ១ដង/ឆ្នាំ | ៣០០ | ២០២០ | ២០២២ |
| យុទ្ធនាការផ្សព្វផ្សាយការយល់ដឹងពីសារៈប្រយោជន៍ធនធានជលផល | ១ដង/ឆ្នាំ | ៣០០ | ២០២០ | ២០២២ |
| យុទ្ធនាការប្រមូលឧបករណ៍នេសាទខុសច្បាប់ | ១ដង/ឆ្នាំ | ១៥០ | ២០២០ | ២០២២ |
| ផ្សព្វផ្សាយពីការប្រមូលប្រាក់បដិភាគ | ១ដង/ឆ្នាំ | ៣០០ | ២០២០ | ២០២២ |

| | | | | |
|---|---|---|---|---|
| ប្រជុំផ្សព្វផ្សាយអំពីតួនាទីរបស់បុរស ស្ត្រីក្នុងសហគមន៍នេសាទ និងការងារផ្ទះ សមភាពនិងសមធម៌យេនឌ័រ | ១ដង/ឆ្នាំ | ៣០០ | ២០២០ | ២០២២ |

### ឃ.៣.៤.ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | ប៉ាន់ប្រមាណថវិកា(ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្ដើម | ថ្ងៃខែឆ្នាំបញ្ចប់ | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|
| ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ដល់សមាជិកសហគមន៍តាមរយៈបុណ្យទាន មហាសន្និបាតប្រចាំឆ្នាំ | ១០០ | ២០២០ | ២០២២ | - គណៈកម្មការ<br>- អាជ្ញាធរឃុំ |
| បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ទៅក្នុងកម្មវិធីវិនិយោគឃុំ | ៥០ | ២០២០ | ២០២២ | |

### ឃ.៣.៥. ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍

ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ ត្រូវបានរៀបចំដូចខាងក្រោម៖

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្ដើម | ថ្ងៃខែឆ្នាំបញ្ចប់ | ចំណូលសរុប(ដុល្លារ) | ផ្សេងៗ |
|---|---|---|---|---|---|
| ភាគទានពីសមាជិកសហគមន៍នេសាទ | ចុះប្រមូលប្រាក់សមាជិកភាព | ២០២០ | ២០២២ | ៥០ | |
| ភាគទានប្រចាំឆ្នាំពីសមាជិក សហគមន៍នេសាទ | ចុះប្រមូលប្រាក់ភាគទានប្រចាំឆ្នាំចំនួន ២.០០០/គ្រួសារ នៃសមាជិកសរុប ៦៣គ្រួសារ | ២០២០ | ២០២២ | ១៧៤ | |
| ភាគទានពីអ្នកនេសាទក្រៅសហគមន៍នេសាទ និងអ្នកមិនចូលជាសមាជិកសហគមន៍នេសាទ | ប្រមូលប្រាក់ភាគទានពីអ្នកនេសាទខាងក្រៅចំនួន៤០នាក់(៥០.០០០រៀល/ទូក/រដូវនេសាទ) | ៨/២០១៩ | ៧/២០២២ | ១.៥០០ | |
| | ប្រមូលប្រាក់អ្នកមិនមែនជាសមាជិកសហគមន៍នេសាចំនួន៣៥នាក់ (៥០.០០០រៀល/ទូក/រដូវនេសាទ) | ៨/២០១៩ | ៧/២០២២ | ១.៣១២ | |
| ភាគលាភពីក្រុមសន្សំប្រាក់ | ភាគលាភប្រចាំឆ្នាំរបស់ក្រុមសន្សំ | ២០២០ | ២០២២ | ៧៥ | |
| **សរុបថវិកាដែលសហគមន៍មាន** | | | | **៣.១១១** | |
| **ប្រាក់ចំណូលពីប្រភពផ្សេងៗ** (ជំនួយពីរាជរដ្ឋាភិបាល ជំនួយពីអង្គការជាតិ និងអង្គការមិនមែនរដ្ឋាភិបាល និងសប្បុរសជន) | • បញ្ចូលផែនការអភិវឌ្ឍសហគមន៍ទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ<br>• ទំនាក់ទំនងជាមួយស្ថាប័នជលផល<br>• សរសេរគម្រោងស្នើសុំពីអង្គការដៃគូ | ២០២០ | ២០២២ | **១១០.៧៨៩** | |
| **សរុបថវិកាដែលគ្រោងចំណាយ** | | | | **១១៣.៩០០** | |

### ង.ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

ការតាមដាន ត្រួពិនិត្យ និងវាយតម្លៃ ត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | ការប៉ាន់ស្មានតម្លៃ (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|
| ប្រជុំផ្ទៃក្នុង ប្រចាំត្រីមាសរបស់គណៈកម្មការសហគមន៍នេសាទ | ១២០ | ២០២០ | ២០២២ | គណៈកម្មការ |
| រៀបចំមហាសន្និបាតសហគមន៍ប្រចាំឆ្នាំ ដោយមានការចូលរួមពីចូលរួមពីស្ត្រី និងអ្នកពាក់ព័ន្ធ | ៣០០ | ២០២០ | ២០២២ | -គណៈកម្មការ<br>-អាជ្ញាធរឃុំ |

### ច.យុទ្ធសាស្ត្រ

ដើម្បីអនុវត្តផែនការឱ្យទទួលបានជោគជ័យយុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំដូចខាងក្រោម ៖

- បង្កើតគណៈកម្មការសម្រាប់អនុវត្ត តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការ រួមមានសមាជិកគណៈកម្មការសហគមន៍នេសាទ ចាស់ទុំ សមាជិកសហគមន៍នេសាទ ដែលមានបទពិសោធន៍ និងចំណេះដឹងល្អ ជាពិសេសអំពីបញ្ហានេសាទ
- ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់លើផែនការណា ដែលទាក់ទងនឹងបច្ចេកទេសជលផលដូចជា ការរៀបចំកន្លែងអភិរក្សព្រៃលិចទឹក កន្លែងអភិរក្សជីវៈចម្រុះ ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី និងការរកថវិកាទ្រទ្រង់ជាដើម
- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការដៃគូ គម្រោង និងម្ចាស់ជំនួយ ដើម្បីទទួលបានការឧបត្ថម្ភគាំទ្រ និងថវិកាសម្រាប់ដំណើរការអនុវត្តផែនការ
- រៀបចំកម្មវិធីអនុវត្តផែនការតាមដំណាក់កាលនីមួយៗឱ្យបានជាក់លាក់
- ទាក់ទងជាមួយរដ្ឋបាលជលផល ដើម្បីសុំការគាំទ្រថវិកា និងជួយរកដៃគូសម្រាប់ទ្រទ្រង់ផែនការគ្រប់គ្រងសហគមន៍នេសាទ
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសបាគមន៍ ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីជំរុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ
- កៀរគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ
- រៀបចំវិធានការចំពោះអ្នកនេសាទមកពីក្រៅសហគមន៍នេសាទ
- ពង្រឹងសមត្ថភាពបច្ចេកទេស និងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទដើម្បីចូលរួមអនុវត្តផែនការ
- បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ទៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ ។

**តារាងសង្ខេបផែនការគ្រប់គ្រងតំបន់នេសាទសហគមន៍កោះឈើទាលតូច រយៈពេល៣ឆ្នាំ (២០២០ ដល់ ២០២២)**

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ប្រភពជំនួយ | ពេលផ្ដើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| **ឃ.១.ធនធានជលផល និងអេកូឡូស៊ី** | | | | | | | |
| ឃ.១.១.ផែនការប្រើប្រាស់ឧបករណ៍នេសាទ | ផ្សព្វផ្សាយពីប្រភេទឧបករណ៍នេសាទ ដែលអនុញ្ញាតទំហំ ពេលវេលា និងទីកន្លែងនេសាទ និងប្រភេទឧបករណ៍នេសាទហាមឃាត់ | ផែនការប្រើប្រាស់ឧបករណ៍នេសាទត្រូវបានផ្សព្វផ្សាយ២ដង ក្នុង១ឆ្នាំ (រដូវបិទ និងបើកនេសាទ) | ៦០០<br>១ដង×១០០×២លើក×៣ឆ្នាំ | -សហគមន៍នេសាទ<br>-រដ្ឋបាលជលផល<br>-អង្គការដៃគូ | ២០២០ | ២០២២ | |
| ឃ.១.២.ផែនការបោះបង្គោលព្រំប្រទល់ និងផ្ទាំងប៉ាណូផែនទីសហគមន៍នេសាទ | ផលិតបង្គោលព្រំធ្វើពីស៊ីម៉ង់ត៍ចំនួន៦ បង្គោលដាក់នៅតាមព្រំប្រទល់ដែននេសាទកោះឈើទាលតូច | - បង្គោលចំនួន៦ដើមត្រូវបានផលិត និងបានបោះនៅតាមព្រំប្រទល់<br>- កាត់បន្ថយបាននូវទំនាស់ព្រំប្រទល់ | ៦០០ | -រដ្ឋបាលជលផល<br>-អង្គការនានា<br>-សប្បុរសជន | ២០២០ | ២០២២ | |
| | ដំឡើងផ្ទាំងប៉ាណូផែនទីចំនួន៣ផ្ទាំង | ផ្ទាំងប៉ាណូផែនទីចំនួន៣ផ្ទាំងបានផលិត និងបានបោះនៅក្នុងសហគមន៍ | ៥០០ | | ២០២០ | ២០២២ | |
| | ស្លាកអប់រំចំនួន៣០ស្លាក | ស្លាកអប់រំត្រូវបានផលិតនិងបានបោះនៅក្នុងសហគមន៍នេសាទ | ១២០ | | ២០២០ | ២០២២ | |
